ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១២ .សរណន

56.19
30.10.2009
ថតចម្លង
នាយកដ្ឋាន.រដ្ឋបាល

# សារាចរណែនាំ

## ស្តីពី

## ការរៀបចំកែសម្រួលប្រាក់បៀវត្សរបស់ទីប្រឹក្សានាយករដ្ឋមន្ត្រី ទីប្រឹក្សាឧបនាយករដ្ឋមន្ត្រី និងទីប្រឹក្សារាជរដ្ឋាភិបាល ព្រមទាំងសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

កន្លងមក រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការតែងតាំងមន្ត្រីមួយចំនួន ជាទីប្រឹក្សាផ្ទាល់របស់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី ជាទីប្រឹក្សារបស់ឧបនាយករដ្ឋមន្ត្រី ជាទីប្រឹក្សារាជរដ្ឋាភិបាលកម្ពុជា ជាសមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដោយផ្តល់ជូននូវ **ឋានៈស្មើ-បន្ថែមលើមុខងារបច្ចុប្បន្ន** ហើយមន្ត្រីទាំងនោះត្រូវបានរៀបចំបៀវត្សជូនតាម **ឋានៈស្មើ** ដែលមានកំរិតខ្ពស់ជាង **ឋានៈនៃមុខងារបច្ចុប្បន្ន** បន្តិច ។

ដោយសារបច្ចុប្បន្ននេះ សភាពការណ៍សេដ្ឋកិច្ចកំពុងជួបប្រទះនឹងផលវិបាកនៃវិបត្តិសេដ្ឋកិច្ចសកល ដែលតម្រូវឱ្យរាជរដ្ឋាភិបាលមានវិធានការសន្សំសំចៃថវិកាជាតិ រាជរដ្ឋាភិបាលសូមណែនាំឱ្យក្រសួង និងស្ថាប័នមានសមត្ថកិច្ច ធ្វើការរៀបចំកែសម្រួលបៀវត្សរបស់មន្ត្រីខាងលើ ដែលត្រូវបានផ្តល់ **ឋានៈស្មើ** ចាប់ពី **អនុរដ្ឋលេខាធិការ** ឡើងលើ ឱ្យទៅទទួលប្រាក់បៀវត្សតាមឋានៈនៃ **មុខងារបច្ចុប្បន្ន** រៀងៗខ្លួនវិញ ។

ទទួលបានសារាចរណែនាំនេះ ឯកឧត្តម លោកជំទាវ រដ្ឋមន្ត្រី និងប្រធានស្ថាប័នមានសមត្ថកិច្ច ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ២៩ ខែ តុលា ឆ្នាំ ២០០៩*

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ*
- *ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ក្រសួង ស្ថាប័នពាក់ព័ន្ធ និងខេត្ត-រាជធានីភ្នំពេញ*
- *ឯកសារ-កាលប្បវត្តិ*